# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្រាប់ការអភិវឌ្ឍប្រេងនៅប្លុក A
# រវាង
# រាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនKrisEnergy

### សណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧

នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា បានរៀបចំពិធីចុះហត្ថលេខា លើកិច្ចព្រមព្រៀងសម្រាប់ការអភិវឌ្ឍប្រេងនៅប្លុក A រវាងរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ជាមួយក្រុមហ៊ុន KrisEnergy តំណាងដោយលោក Kelvin Tang **នាយកប្រតិបត្តិ ក្រុមហ៊ុន KrisEnergy Group និងជាប្រធានក្រុមហ៊ុន KrisEnergy (Cambodia)** លើកញ្ចប់ឯកសារកិច្ចព្រមព្រៀងប្រេងកាត ប្លុក A ដូចខាងក្រោម៖

**១- កិច្ចព្រមព្រៀងវិសោធនកម្ម និងការថែងឡើងវិញ នៃកិច្ចព្រមព្រៀងប្រេងកាតប្លុក A ចុះថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០០២**
**២- កិច្ចព្រមព្រៀងប្រេងកាតប្លុក A ក្រោយធ្វើវិសោធនកម្មរួច និងការថែងឡើងវិញ**
**៣- កិច្ចព្រមព្រៀងប្រគល់ផ្ទៃក្រឡាសងវិញ**
**៤- វិសោធនកម្មកិច្ចព្រមព្រៀងប្រតិបត្តិការរួមគ្នា**
**៥- កិច្ចសន្យាប្រគល់សិទ្ធិ និងទទួលយកកាតព្វកិច្ច**
**៦- លិខិតអនុញ្ញាតផលិតកម្មលើកទី១**

ការចុះហត្ថលេខាលើកញ្ចប់កិច្ចព្រមព្រៀងសម្រាប់ការអភិវឌ្ឍអណ្តូងប្រេងកាតអប្សរានៃប្លុក A នាពេលនេះគឺជាសក្ខីភាពឆ្លុះបញ្ចាំងនូវសមិទ្ធិផលដ៏អស្ចារ្យថ្មីថែមទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។ គម្រោងប្រេងកាតប្លុក A នេះ គឺជាគម្រោងប្រេងកាតទី១ ដែលបើកសករាជឱ្យកម្ពុជាក្លាយជាប្រទេសផលិតប្រេងនិងឈានទៅធ្វើការស្វែងរុករកដ៏ខ្លាំងក្លាថែមទៀត លើប្លុកប្រេងកាត ដែលនៅទំនេរចំនួន៥ប្លុកទៀត ក្នុងចំណោមប្លុកប្រេងកាតចំនួន ៦ នៅដែនសមុទ្រ និង១៨ប្លុក នៅដែនគោក។

ដើម្បីអភិវឌ្ឍវិស័យប្រេងកាតនេះ រាជរដ្ឋាភិបាលកំពុងខិតខំជំរុញរៀបចំបញ្ចប់ច្បាប់ស្តីពីការគ្រប់គ្រងវិស័យប្រេងកាត និងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ដើម្បីធានាដល់បរិស្ថានវិនិយោគ និងភាពច្បាស់លាស់ ក្នុងការដាក់ទុនវិនិយោគរបស់វិស័យឯកជន។ ជាក់ស្តែងថ្មីៗនេះ មានក្រុមហ៊ុនមួយចំនួនកំពុងមានចំណាប់អារម្មណ៍លើប្លុកប្រេងកាត ដែលនៅទំនេរនានា ចំណាប់អារម្មណ៍លើការវិនិយោគសាងសង់រោងចក្រចំរាញ់ប្រេងកាត បំពង់បង្ហូរប្រេង និងឧស្ម័ន ក៏ដូចជាការនាំចូលឧស្ម័នធម្មជាតិ(LNG) ដែលជាប្រភពថាមពលស្អាត និងកំពុងពេញនិយមនៅលើពិភពលោក។

កម្ពុជាធ្លាប់មានក្រុមហ៊ុន Elf និង ក្រុមហ៊ុន Esso ខួងអណ្តូងប្រេងកាតជាលើកដំបូងបង្អស់នៅក្នុងចន្លោះឆ្នាំ ១៩៧២ និង ឆ្នាំ ១៩៧៤ ក៏ប៉ុន្តែពុំទាន់បានរកឃើញធនធានប្រេងកាតនោះទេ។ ក្រោយមកក្នុងឆ្នាំ ១៩៩៤ ក្រុមហ៊ុន Enterprise Oil របស់ចក្រភពអង់គ្លេសបានខួងរកឃើញប្រេងកាតចំនួន ២អណ្តូង ប៉ុន្តែនៅតែមិនអាចអភិវឌ្ឍបានដោយសារកត្តាទំហំប្រេងមានកម្រិត និងតម្លៃប្រេងនៅថោកនៅឡើយ។ រហូតមកដល់ឆ្នាំ២០០២ ដែលកិច្ចព្រមព្រៀងប្រេងកាត ត្រូវបានចុះហត្ថលេខាជាលើកដំបូង ជាមួយក្រុមហ៊ុន Chevron និងមានការចូលរួមភាគហ៊ុនពី KrisEnergy ក្នុងឆ្នាំ២០១១ ឆ្នាំ២០១៤ និងឆ្នាំ២០១៦ ជាបន្តបន្ទាប់ រហូតដល់ក្រុមហ៊ុន KrisEnergy បានក្លាយជាប្រតិបត្តិករ និងមានភាគហ៊ុនសរុបចំនួន ៩៥% និងរាជរដ្ឋាភិបាលកម្ពុជាចំនួន៥%។ ប៉ុន្តែការចរចាត្រូវអូសបន្លាយពេលជាយូរក្នុងការធ្វើឱ្យការអភិវឌ្ឍប្រេងកាតលេចជារូបរាងឡើង។ ការអូសបន្លាយនេះ គឺម្យ៉ាងដោយសារយើងមានការប្រុងប្រយ័ត្នខ្ពស់បំផុត ដោយខិតខំចរចា យ៉ាងស្វិតស្វាញជាមួយក្រុមហ៊ុន ពិនិត្យសិក្សាមូលដ្ឋានច្បាប់ និងបច្ចេកទេសច្បាស់លាស់ ដកពិសោធន៍ពីប្រទេសផលិតប្រេងផ្សេងៗទៀត ដើម្បីការពារផលប្រយោជន៍ជាតិឱ្យបានជាអតិបរមា ធានាបាននូវតម្លាភាព និងគណនេយ្យភាព ម្យ៉ាងទៀតដោយសារភាពមិនអំណោយផលនៃសេដ្ឋកិច្ចសកលលោក ជាពិសេស តម្លៃប្រេងដែលឡើងចុះមិនអាចប៉ាន់ស្មានបាន។

កញ្ចប់កិច្ចព្រមព្រៀងសម្រាប់ការអភិវឌ្ឍអណ្តូងប្រេងកាតនៅប្លុកA ដែលយើងចុះហត្ថលេខាថ្ងៃនេះ នឹងអនុញ្ញាតឱ្យក្រុមហ៊ុនធ្វើផលិតកម្មលើកទី១របស់ខ្លួន គឺជំហាន 1A និង 1B នៃដំណាក់កាលទី១ នៃប្លុក A។ ផ្ទៃក្រឡាដែលនៅសល់បច្ចុប្បន្ន មានចំនួន ៣ ០៨៣គម$^{២}$ ហើយលិខិតអនុញ្ញាតផលិតកម្មទី១ នេះសម្រាប់ជំហាន 1A និង1B ដែលមានផ្ទៃក្រឡា ១៩៨ គម$^{២}$ ចំណែកផ្ទៃក្រឡាផ្សេងទៀតក្រុមហ៊ុនត្រូវធ្វើការសិក្សាបន្ថែមមុននឹងត្រូវសងវិញតាមផែនការដែលបានកំណត់។ យោងតាមផែនការភិវឌ្ឍរបស់ក្រុមហ៊ុន តំណក់ប្រេងដំបូងរបស់ជំហាន 1A នឹងផលិតប្រេងដំបូង ក្នុងរយៈពេល ២ឆ្នាំទៀត គឺនៅចុងឆ្នាំ ២០១៩ ឬដើមឆ្នាំ២០២០។ យោងតាមកិច្ចព្រមព្រៀងនេះ បន្ទាប់ពីចុះហត្ថលេខារួច ក្រុមហ៊ុនត្រូវការពេលវេលាចំនួន ៦០ ថ្ងៃ ដើម្បីទទួលបានការសម្រេចចិត្តវិនិយោគចុងក្រោយ (FID) បន្ទាប់មកក្រុមហ៊ុនត្រូវសាងសង់ហេដ្ឋារចនាសម្ព័ន្ធរយៈពេល២៤ខែ ដើម្បីផលិតបានប្រេងលើកដំបូង។

តំបន់កិច្ចសន្យាប្លុក A កម្ពុជា មានទំហំ ៣,០៨៣ គីឡូម៉ែត្រការ៉េ ដែលស្ថិតនៅក្នុងអាងសមុទ្រខ្មែរ ក្នុងតំបន់ឈូងសមុទ្រថៃ ដែលមានជម្រៅទឹកចន្លោះពី ៥០ម៉ែត្រ ទៅ ៨០ម៉ែត្រ ។ ដំណាក់កាល 1A នៃគម្រោងអភិវឌ្ឍន៍អណ្តូងប្រេងអប្សរា រួមមានផ្លាតហ្វមក្បាលអណ្តូងផលិតកម្មដែលបញ្ជាពីចម្ងាយ មួយទ្រទ្រង់ដល់អណ្តូងបូមប្រេងចំនួន ២៤ ដែលបញ្ជូនសន្ទនីយ (fluid) ដែលបូមបាន ក្នុងបរិមាណ ៣ម៉ឺនបារ៉ែលក្នុងមួយថ្ងៃ ទៅកាន់នាវាផលិតកម្មមួយដែលអាចប្រព្រឹត្តកម្មប្រេង ដោយញែកយកឧស្ម័ន ប្រេង និងទឹកចេញពីគ្នា។ ប្រេងនៅដែលញែកបាន ប្រមាណ ៨ ០០០បារ៉ែល ក្នុងមួយថ្ងៃ យោងតាមក្រុមហ៊ុន KrisEnergy នឹងត្រូវបញ្ជូនតាមបំពង់បង្ហូរប្រេងប្រវែង ១,៥គីឡូម៉ែត្រ ទៅកាន់នាវាបណ្តែតផ្ទុក និងផ្ទេរប្រេង ហៅកាត់ថា FSO ។

ការគាំពារបុគ្គលិក បរិក្ខារ និងបរិស្ថាន នឹងត្រូវទទួលបានការយកចិត្តទុកដាក់ខ្ពស់ក្នុងអំឡុងពេលអភិវឌ្ឍប្លុក A ។ ដើម្បីធានាអោយបាននូវចំណុចទាំងនេះ យើងបានបង្កើតផែនការសុវត្ថិភាពជាច្រើន ដែលគ្របដណ្តប់រាល់បញ្ហាសុខភាព និងសុវត្ថិភាពទាំងអស់ ក្នុងអំឡុងពេលរៀបចំគ្រោងការប្លង់ ការសាងសង់ និងធ្វើប្រតិបត្តិការ ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ("EIA") ត្រូវបានធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិស្តីពីបរិស្ថាននៃប្រទេសកម្ពុជា និងបានអនុម័តដោយក្រសួងបរិស្ថាន កាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ។ ក្រុមហ៊ុន KrisEnergy ត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានស្រាប់នេះ ដើម្បីអាចគ្របដណ្តប់ការងារអភិវឌ្ឍន៍ថ្មីៗនានា ។

រាជរដ្ឋាភិបាលនឹងបន្តគាំទ្រ បង្ករលក្ខណៈងាយស្រួលសព្វបែបយ៉ាង និងពុះពារដើម្បីសម្រេចឱ្យបាននូវការចេញលិខិតបទដ្ឋានពាក់ព័ន្ធនឹងគម្រោងវិនិយោគប្រេងកាតប្លុក A នេះ តាមការព្រមព្រៀងដោយអនុលោមតាមច្បាប់ និងរបបលើកទឹកចិត្តជាធរមាន ដើម្បីធ្វើឱ្យគម្រោងវិនិយោគប្រេង និងឧស្ម័ន ក្នុងប្លុក A ទទួលជោគជ័យ តាមការគ្រោងទុក។ ដូចគ្នាដែរ ភាគីក្រុមហ៊ុន ត្រូវបំពេញកាតព្វកិច្ចពាក់ព័ន្ធនានា ដូចមានចែងក្នុងកញ្ចប់កិច្ចព្រមព្រៀងប្រេងកាតប្លុក A។

ប្រតិបត្តិការដោយរលូន និងជោគជ័យរបស់ក្រុមហ៊ុន KrisEnergy ក្នុងដំណាក់កាលទី ១ នៃប្លុក A នឹងបើកផ្លូវពន្លឿនសន្ទុះសម្រាប់ផែនការស្វែងរុករក វាយតម្លៃ និងអភិវឌ្ឍធនធានប្រេងកាត នៅដំណាក់កាលទី ២ និងទី៣ នៅក្នុងប្លុក A ទាំងមូល បន្តទៀត ក៏ដូចជាការចរចា និង រៀបចំកិច្ចព្រមព្រៀងក្នុងប្លុកផ្សេងទៀត។

ការវិនិយោគក្នុងទំហំទឹកប្រាក់ដ៏ធំនេះ ជាសញ្ញាបញ្ជាក់ពីការជឿទុកចិត្តរបស់វិនិយោគិនមកលើស្ថិរភាពនយោបាយ សន្តិសុខ និងបរិស្ថានវិនិយោគអំណោយផលរបស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចាត់ទុកជា ***ខ្លាសេដ្ឋកិច្ចថ្មីនៅ អាស៊ី*** ក្រោមការដឹកនាំដ៏ភ្លឺស្វាង ប្រកបដោយចក្ខុវិស័យ

វែងឆ្ងាយ និងភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។